NEWS RELEASE

UNITED NATIONS HUMAN RIGHTS OFFICE OF THE HIGH COMMISSIONER

# ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស អ.ស.ប អំពាវនាវឲ្យប្រកាន់ខ្ជាប់អភិក្រមសិទ្ធិមនុស្ស ក្នុងការប្រយុទ្ធប្រឆាំងនឹងកូវីដ១៩

ទីក្រុងហ្សឺណែវ (២៤ មីនា ២០២០) - កាលពីថ្ងៃអង្គារនេះ គណៈប្រធានសន្ធិសញ្ញា អ.ស.ប ចំនួន ១០ ស្ថាប័ន បានជំរុញឲ្យមេដឹកនាំពិភពលោកទាំងអស់ ធានាការគោរពសិទ្ធិមនុស្សនៅក្នុងវិធានការផ្សេងៗរបស់រដ្ឋាភិបាល ក្នុងការដោះស្រាយការគំរាមកំហែងសុខភាពសាធារណៈ ដែលបង្កឡើងដោយការរាតត្បាតនៃកូវីដ១៩។

"មានតែធ្វើតាមរយៈការរាប់បញ្ចូលមនុស្សទាំងអស់ទៅក្នុងយុទ្ធសាស្ត្រកូវីដ១៩ ទេ ដែលអាចប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺនេះបាន" នេះបើតាមប្រសាសន៍របស់លោកស្រី Hilary Gbedemah ប្រធានគណៈកម្មការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងដែលបច្ចុប្បន្នជាប្រធានក្រុម ដែលប្រមូលផ្តុំដោយប្រធានគណៈកម្មាធិការនីមួយៗ។

អ្នកជំនាញទាំង ១០ រូប នេះ បានអំពាវនាវដល់រដ្ឋនានាឲ្យប្រកាន់យកវិធានការផ្សេងៗ ដើម្បីការពារសិទ្ធិរស់រានមានជីវិត និងសិទ្ធិសុខភាព និងធានាការទទួលបានកិច្ចគាំពារសុខភាពដល់អ្នកទាំងអស់ដែលត្រូវការកិច្ចគាំពារនេះ ដោយគ្មានការរើសអើង។ អ្នកជំនាញបានស្នើយ៉ាងទទូចដល់រដ្ឋាភិបាលនានា ឲ្យយកចិត្តទុកដាក់បន្ថែមចំពោះអ្នកដែលងាយរងគ្រោះពីផលប៉ះពាល់នៃកូវីដ១៩ រួមមាន ជនចាស់ជរា ជនពិការ ជនជាតិភាគតិច ជនជាតិដើមភាគតិច ជនភៀសខ្លួន អ្នកស្វែងរកសិទ្ធិជ្រកកោន និងជនចំណាកស្រុក ជនដែលត្រូវគេដកហូតសិទ្ធិសេរីភាព ជនអនាថា និងជនដែលរស់នៅក្នុងភាពក្រីក្រ។ អ្នកជំនាញបានសង្កត់ធ្ងន់ផងដែរថា ស្ត្រីមានហានិភ័យខ្ពស់ដែលមិនសមាមាត្រ ពីព្រោះនៅក្នុងសង្គមជាច្រើន ពួកគេជាអ្នកថែរក្សាដ៏សំខាន់ដល់សមាជិកគ្រួសារដែលមានជំងឺ។

លោកស្រី Gbedemah មានប្រសាសន៍ថា "គ្មាននរណាម្នាក់ត្រូវបានគេបដិសេធចំពោះកិច្ចគាំពារសុខភាពដោយសារតែការមាក់ងាយ (ស្ទិកម៉ា) ឬដោយសារតែពួកគេជាសមាជិកនៃក្រុមដែលបាត់បង់ឱកាសឡើយ" លោកស្រីបានបន្តទៀតថា "រដ្ឋនានា ត្រូវផ្តល់ការគាំទ្រជាគោលដៅ រួមទាំង ការគាំទ្រផ្នែកហិរញ្ញវត្ថុ សង្គម និងសារពើពន្ធ ដល់អ្នកដែលរងផលប៉ះពាល់ជាពិសេស ដូចជា អ្នកដែលមិនមានធានារ៉ាប់រងសុខភាព ឬសន្តិសុខសង្គម។"

ការគាំទ្រជាគោលដៅនេះ គួរតែពង្រីកទៅដល់សិទ្ធិផ្សេងៗទៀត។ នៅក្នុងប្រទេសដែលអនុវត្តការរឹតត្បិតទូទៅលើការដើរហើរ រដ្ឋាភិបាលគួរតែប្រើគ្រប់មធ្យោបាយដែលមាន រួមទាំង ការសិក្សាពីចម្ងាយ ដើម្បីបន្តទទួលបាន

ការអប់រំ ជាពិសេសសម្រាប់កុមារ និងមនុស្សវ័យជំទង់។ និស្សិតពិការក៏គួរតែមានសិទ្ធិទទួលបានឱកាសអប់រំដូចគ្នាផងដែរ។ រដ្ឋនានា គួរតែធានាផ្តត់ផ្គង់ទំនិញ និងសេវាកម្មសំខាន់ចាំបាច់ផ្សេងៗ ដល់ជនងាយរងគ្រោះបំផុត ដោយមិនត្រូវទុកនរណាម្នាក់ចោលឡើយ។

គណៈប្រធានបានព្រមានថា ការភ័យខ្លាច និងភាពមិនប្រាកដប្រជាពីជំងឺរាតត្បាតនេះ អាចនាំទៅដល់ការប្រើល្បិចស្វាស៊ីបាយលាបមាត់ពពៃ និងការរើសអើង។ លោកស្រី Gbedemah បានមានប្រសាសន៍ថា "រដ្ឋនានាត្រូវតែចាត់វិធានការយ៉ាងសកម្ម ដើម្បីធានាឲ្យមានស្មារតីសាមគ្គីភាពជាធំ រួមទាំងតាមរយៈការការពារប្រឆាំងនឹងការរើសអើងជាតិសាសន៍ និងការស្អប់ខ្ពើមជនបរទេស ឬសន្ទុះនៃជាតិនិយមដែលមិនអាចគ្រប់គ្រងបាន"។

មានចំនួនរដ្ឋកាន់តែច្រើនឡើងៗ បានដាក់ការត្រួតពិនិត្យយ៉ាងតឹងរ៉ឹងធ្វើឲ្យប៉ះពាល់ដល់សិទ្ធិមនុស្ស ដូចជាការកម្រិតកំណត់លើសិទ្ធិសេរីភាពក្នុងការដើរហើរ និងការរឹតត្បិតលើការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិឯកជន ជាដើម។

"ការត្រួតពិនិត្យទាំងនេះ ត្រូវតែបានធ្វើឡើងស្របតាមក្របខណ្ឌច្បាប់ជាធរមាន។ នៅក្នុងបណ្តាប្រទេសដែលប្រកាសដាក់ប្រទេសក្នុងភាពអាសន្ន សេចក្តីប្រកាសបែបនេះ ត្រូវតែមានលក្ខណៈពិសេស និងជាបណ្តោះអាសន្ន មានលក្ខណៈចាំបាច់បំផុត ហើយត្រូវមានបញ្ជាក់ពីហេតុផលត្រឹមត្រូវ ដោយសារតែការគំរាមកំហែងដល់អាយុជីវិតរបស់ប្រទេសជាតិ។" នេះបើតាមប្រសាសន៍របស់លោកស្រី Hilary Gbedemah។

លោកស្រីបានបន្តទៀតថា "ការប្រកាសដាក់ប្រទេសក្នុងភាពអាសន្ន ឬវិធានការណ៍សន្តិសុខណាមួយផ្សេងទៀតគួរតែធ្វើឡើងដោយផ្អែកតាមគោលការណ៍សិទ្ធិមនុស្ស ហើយមិនគួរប្រើធ្វើជាលេស ដើម្បីបញ្ឈប់ដោយបង្ខំនូវគំនិតប្រឆាំងឡើយ"។

ចប់

*សន្ធិសញ្ញាសិទ្ធិមនុស្សចំនួន ១០ របស់អង្គការសហប្រជាជាតិ គឺជាសន្ធិសញ្ញាដែលជាប់កាតព្វកិច្ចអនុវត្តតាមផ្លូវច្បាប់ ដែលមហាសន្និបាត អ.ស.ប បានអនុម័ត ហើយរដ្ឋនានាបានផ្តល់សច្ចាប័ន។ ស្ថាប័នសន្ធិសញ្ញាទាំង១០ ឬគណៈកម្មាធិការ មានដូចជា គណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ គណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងជាតិសាសន៍ គណៈកម្មាធិការសិទ្ធិជនពិការ គណៈកម្មាធិការសិទ្ធិកុមារ គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ គណៈកម្មាធិការប្រឆាំងទារុណកម្ម និងអនុគណៈកម្មាធិការនេះ ដែលទទួលបន្ទុកការបង្ការ ទប់ស្កាត់ទារុណកម្ម គណៈកម្មាធិការទទួលបន្ទុកការបំបាត់ខ្លួនដោយបង្ខំ និងគណៈកម្មាធិការទទួលបន្ទុកពលករទេសន្តរប្រវេសន៍C។*

*គណៈកម្មាធិការនីមួយៗត្រូវបានបង្កើតឡើង តាមរយៈសន្ធិសញ្ញាមួយ និងបានបង្កើតជាក្រុមអ្នកជំនាញឯករាជ្យ ដែលជាប់ឆ្នោត ដែលព្យាយាមធានាថា រដ្ឋនានា អាចបំពេញកាតព្វកិច្ចស្របច្បាប់របស់ពួកគេ ក្រោមឯកសារច្បាប់នោះ។ ប្រព័ន្ធនៃការត្រួតពិនិត្យឯករាជ្យ នៃសកម្មភាព ឬការប្រព្រឹត្តរបស់រដ្ឋទាំងឡាយ ដោយអ្នកជំនាញឯករាជ្យ គឺជាធាតុមួយដ៏សំខាន់នៃប្រព័ន្ធសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដែលគាំទ្រដោយលេខាធិការដ្ឋាន នៅក្នុងការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស។*

សម្រាប់ការស្នើសុំព័ត៌មាន សូមទាក់ទងលោក *Vivian Kwok* នៅទីក្រុងហ្សឺណែវតាមរយៈលេខ +៤១ ២២ ៩១៧ ៩៣៦២ / អ៊ីម៉ែល vkwok@ohchr.org

***ស្វែងយល់បន្ថែមជាមួយគំនូរជីវចលរបស់យើងស្តីពីប្រព័ន្ធស្ថាប័នសន្ធិសញ្ញា!***

សូមសិក្សាស្វែងយល់ពីការិយាល័យសិទ្ធិមនុស្សអ.ស.ប នៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម! យើងស្ថិតនៅលើ ធ្វីតធ័រ @UNHumanRights, ហ្វេសប៊ុក Facebook @unitednationshumanrights និង អាំងស្តាក្រាម @unitednationshumanrights